





# ក្បួនខ្នាតសុវត្ថិភាពនៃម្ហូបអាហារ-តម្រូវការសំរាប់លិខិតប្រាប់ឲ្យដឹងនៃពាណិជ្ជកម្មម្ហូបអាហារ

## ជំពូកទី៣ (សំរាប់តែប្រទេសអូស្ត្រាលី)ច្បាប់ស្តីពីក្បួនខ្នាតខាងម្ហូបអាហារនៃអូស្ត្រាលី ញ៉ូវហ្សឺលែន

*កំណត់សំគាល់៖ ក្បួនខ្នាតសុវត្ថិភាពនៃម្ហូបអាហារថ្មីពុំអនុវត្តនៅក្នុងប្រទេសញ៉ូវហ្សឺលែនទេ ។ លក្ខខ័ណ្ឌដែលមាន ចែងក្នុងសិទ្ធិសញ្ញាក្បួនខ្នាតនៃម្ហូបអាហាររវាងប្រទេសអូស្ត្រាលីនិងញ៉ូវហ្សឺលែន ពុំមានរាប់បញ្ចូលក្នុងក្បួនខ្នាត អនាម័យខាងម្ហូបអាហារទេ ។*

## តើលិខិតប្រាប់ឲ្យដឹងនៃតម្រូវការអនុវត្តចំពោះអ្នកណា?

លិខិតប្រាប់ឲ្យដឹងនៃតម្រូវការត្រូវអនុវត្តទៅលើពាណិជ្ជកម្មសឹងតែទាំងអស់នៅក្នុងប្រទេសអូស្ត្រាលី។ ពាណិជ្ជកម្មម្ហូបអាហារគឺជាពាណិជ្ជកម្ម ឬសកម្មភាពដែលទាក់ទងនឹងការលក់ដូរម្ហូបអាហារ ឬការចាប់កាន់ម្ហូបអាហារមួយ ប្រភេទសំរាប់លក់នៅក្នុងប្រទេសអូស្ត្រាលី, លើកលែងតែសកម្មភាពខ្លះៗនៃផលិតកម្មធាតុដើមនៃម្ហូបអាហារ ។

នេះមានន័យថា តម្រូវការនៃលិខិតប្រាប់ឲ្យដឹងអនុវត្តលើសកម្មភាពដែលធ្វើដោយមូលហេតុសំរាប់សហគមន៍ ឬ សំរាប់សង្គ្រោះ, រួមជាមួយការផ្សងព្រេងពាណិជ្ជកម្មហើយគំរោងការណ៍ "តែមួយដង" ដែលជាប់ទាក់ទងនឹងការចាប់កាន់ ម្ហូបអាហារ។ នេះរាប់បញ្ចូលពាណិជ្ជកម្មដែលគេមិនយល់ថាជាពាណិជ្ជកម្មម្ហូបអាហារ, ដូចជា ឧសថស្ថាន, រោងភាពយន្ត, ហាងតូចៗ, ហាងលក់សាំងនិងអាងហែលទឹក, ប្រសិនបើគេលក់ម្ហូបអាហារជាកញ្ចប់ ឬជាបែបយ៉ាងឯទៀតៗ។

ការលើកលែងគឺមានចុះដូចខាងក្រោមនេះ ។

- ពាណិជ្ជកម្មដូចជាស្រែ, ចំការទំពាំងបាយជូរ, ចំការផ្លែឈើ ឬចំការដាំនៅក្នុងទឹក, ឲ្យតែគេមិនលក់ ឬផ្តល់ម្ហូបអាហារផ្ទាល់ ទៅសាធារណៈជន ឬធ្វើម្ហូបអាហារពីអ្វីដែលគេផលិត។
- គេមិនត្រូវការលិខិតប្រាប់ឲ្យដឹងទេសំរាប់ម៉ាស៊ិនលក់ម្ហូបអាហារដោយឡែក ឬរថយន្តដែលប្រើសំរាប់តែដឹកជញ្ជូនម្ហូបអាហារ, ប៉ុន្តែពាណិជ្ជកម្មដែលប្រើម៉ាស៊ិនលក់ម្ហូបអាហារនិងរថយន្តដឹកជញ្ជូនម្ហូបអាហារនឹងត្រូវផ្តល់លិខិតប្រាប់ឲ្យដឹង សំរាប់ពាណិជ្ជកម្មរបស់គេ។

ក្រុមសហគមន៍និងក្រុមសង្គ្រោះគួររកឱវាទមុននឹងដាក់លិខិតប្រាប់ឲ្យដឹងទៅឲ្យភ្នាក់ងារអនុវត្តច្បាប់នៃតំបន់របស់គេដូចជា ការរៀបចំឲ្យបានស្រួលប្រហែលអនុវត្តនៅក្នុងរដ្ឋឬដែនដីរបស់លោកអ្នក ។ តាមវិន័យធម្មតា, យ៉ាងណាក៏ដោយ, គេនឹង ត្រូវប្រាប់ភ្នាក់ងារអនុវត្តច្បាប់ត្រឹមត្រូវនៅពេលដែលគេមានផែនការណ៍ធ្វើព្រឹត្តិការណ៍ដែលទាក់ទងនឹងការលក់ដូរម្ហូបអាហារ ។

## តើខ្ញុំធ្វើអ្វីខ្លះប្រសិនបើខ្ញុំបានចុះឈ្មោះ ឬមានសិទ្ធិជាពាណិជ្ជកម្មម្ហូបអាហាររួចហើយ ?

មិនចាំបាច់ធ្វើអ្វីឡើយ ។ គេត្រូវការលិខិតប្រាប់ឲ្យដឹងដើម្បីធ្វើឲ្យប្រាកដថាភ្នាក់ងារអនុវត្តច្បាប់ដឹងពីពាណិជ្ជកម្មម្ហូបអាហារ នៅក្នុងតំបន់របស់គេនិងរបៀបទាក់ទងទៅគេ, និងផ្តល់ការណែនាំស្តីពីគ្រោះថ្នាក់នៃសុវត្ថិភាពនៃម្ហូមអាហារដែលជាប់ ទាក់ទិននឹងពាណិជ្ជកម្មលោកអ្នក។ រដ្ឋនិងដែនដីនឹងសម្រេចតទៅទៀតលើតម្រូវការនៃការចុះឈ្មោះសំរាប់ពាណិជ្ជកម្មម្ហូបអាហារនៅក្នុងរដ្ឋ ឬដែនដីគេនិងតម្រូវនៃការចុះឈ្មោះរបស់គេនឹងបន្តអនុវត្តក្រោមក្រឹត្យថ្មីនៃម្ហូបអាហារ ។
ប្រសិនបើលោកអ្នកត្រូវបានទទួលស្គាល់ដោយតម្រូវការនៃការចុះឈ្មោះហើយលោកអ្នកនិងមិនប៉ះពាល់ដោយតម្រូវការនៃលិខិតប្រាប់ឲ្យដឹងថ្មីទេ ។ តម្រូវការនៃលិខិតប្រាប់ឲ្យដឹងអនុវត្តតែពាណិជ្ជកម្មម្ហូបអាហារដែលមិនទាន់បានចុះឈ្មោះនិងចំពោះពាណិជ្ជកម្មម្ហូបអាហារនៅក្នុងរដ្ឋណាដែលមិន ទាន់មានប្រព័ន្ធនៃការចុះឈ្មោះសំរាប់ពាណិជ្ជកម្មម្ហូបអាហារនៅឡើយ ។

## តើខ្ញុំធ្វើអ្វីខ្លះប្រសិនបើខ្ញុំមិនទាន់បានចុះឈ្មោះ ឬមានសិទ្ធិជាពាណិជ្ជកម្មម្ហូបអាហារ?

នៅក្រោមច្បាប់លេខ៣.២.២ ប្រតិបត្តិសុវត្ថិភាពនៃម្ហូបអាហារនិងតម្រូវការទូទៅ (Under Standard 3.2.2 Food Safety Practices and General Requirements), ពាណិជ្ជកម្មម្ហូបអាហារត្រូវឲ្យពត៌មានដូចតទៅនេះទៅភ្នាក់ងារអនុវត្តច្បាប់ដែលទទួលខុសត្រូវ ខាងសុវត្ថិភាពនៃម្ហូបអាហារនៅក្នុងតំបន់របស់គេ ។ តាមធម្មតា, នេះគឺជាសាលាសង្កាត់គេ, តែនៅក្នុងរដ្ឋនិងដែនដីខ្លះ វាប្រហែលជាក្រសួងសុខភាព ឬក្រុមសុខភាពសាធារណៈ ឬក្រុមសុខភាពនៃបរិស្ថាន, ស្រេចតែស្ថានភាពនៅក្នុងអំណាចច្បាប់និមួយៗ ។

លិខិតប្រាប់ឲ្យដឹងមិនមែនជារបៀបទទួលយល់ព្រមទេហើយលោកអ្នកមិនត្រូវស្របទៅតាមលក្ខខ័ណ្ឌណាមួយឡើយ ។ យ៉ាងណាក៏ដោយ, លោកអ្នកត្រូវផ្តល់ឲ្យភ្នាក់ងារអនុវត្តច្បាប់នូវ ៖



**ការបកប្រែភាសានេះបានទទួលការឧបត្ថម្ភទាំងស្រុងពីក្រសួងសហព័ន្ធខាងសុខភាពនិងការ ថែរក្សាមនុស្សចាស់**

- ពត៌មានពិស្តារសំរាប់ទាក់ទងនឹងពាណិជ្ជកម្មលោកអ្នកដែលមានបញ្ចូលឈ្មោះពាណិជ្ជកម្ម, ឈ្មោះនិងអស័យដ្ឋានពាណិជ្ជកម្មរបស់ម្ចាស់ពាណិជ្ជកម្ម ។
- ពត៌មានស្តីពីប្រភេទនៃពាណិជ្ជកម្មដើម្បីជួយភ្នាក់ងារអនុវត្តច្បាប់ប៉ាន់មើលកំរិតគ្រោះថ្នាក់សុវត្ថិភាពនៃម្ហូបអាហារទាក់ទិននឹងពាណិជ្ជកម្មលោកអ្នក- ដោយបញ្ចូលពត៌មានស្តីពីប្រភេទពាណិជ្ជកម្ម (ដូចជាអ្នកលក់រាយ, ផលិតករ, ដឹកជញ្ជូន, អ្នកផ្តល់ម្ហូបអាហារ, ភោជ្ជនីយដ្ឋាន, ឬតូបផ្សារ ), ម្ហូបអាហារដែលគេធ្វើឬផ្តល់, ទំហំពាណិជ្ជកម្មនិងសំណួរជាក់លាក់ទាក់ទងនឹងការផ្តល់ផលិតផលដែលមានគ្រោះថ្នាក់ខ្ពស់ និងផ្តល់ផលិតផលទៅក្រុមប្រជាជនដែលនឹងអាចមានគ្រោះថ្នាក់បំផុតពីជម្ងឺដែលបណ្តាលមកពីម្ហូបអាហារមិនស្អាត; ហើយនិង
- ទីតាំងនៃហាងលោកអ្នកទាំងអស់នៅក្នុងតំបន់របស់ភ្នាក់ងារអនុវត្តច្បាប់;

អ្នកលក់ម្ហូបអាហារចល័តក៏ត្រូវផ្តល់ពត៌មានស្តីពីទីកន្លែងដែលគេធ្វើការ និង/ឬ ពត៌មានពីទីកន្លែងដែលគេចត ឬដាក់រថយន្តគេ ។

## ពេលណាតម្រូវការនៃលិខិតប្រាប់ឲ្យដឹងនឹងត្រូវចាប់អនុវត្ត?

នៅក្រោមច្បាប់លេខ៣.២.២ ប្រតិបត្តិសុវត្ថិភាពនៃម្ហូបអាហារនិងតម្រូវការទូទៅ (Under Standard 3.2.2 Food Safety Practices and General Requirements), តម្រូវការនៃលិខិតប្រាប់ឲ្យដឹងអាចត្រូវគេអនុវត្ត ពីខែកុម្ភះ ឆ្នាំ២០០២ ។
យ៉ាងណាក៏ដោយថ្ងៃខែយឺតយូរអាចមាននៅក្នុងរដ្ឋនិងដែនដីខ្លះៗ ។ នេះថិតនៅលើថ្ងៃខែដែលរដ្ឋ ឬដែនដីកែប្រែច្បាប់ម្ហូបអាហារនិងវិន័យរបស់គេ ដើម្បីអនុម័តច្បាប់ថ្មី និងគេអាចជ្រើសរើសពេលបង្ហាញថ្មីចំនួនពេល ១២ ខែសំរាប់តម្រូវការថ្មីឬសម្រេចទុកខែកុម្ភះ២០០២ ជាថ្ងៃខែចាប់ផ្តើមសំរាប់តម្រូវការនេះ ។

ចំពោះពាណិជ្ជកម្មដែលមានពីមុនមក, លិខិតប្រាប់ឲ្យដឹងត្រូវតែធ្វើនៅក្នុងពេល៣ខែនៃថ្ងៃខែនោះ ។ ចំពោះពាណិជ្ជកម្ម ម្ហូបអាហារថ្មីៗវិញ, តម្រូវការនឹងអនុវត្តភ្លាមៗនៅពេលគេអនុវត្តតម្រូវការនៅក្នុងរដ្ឋនិងដែនដីនិមួយៗ និងលិខិតប្រាប់ឲ្យដឹងត្រូវតែធ្វើឲ្យបានមុនពាណិជ្ជកម្មចាប់បើកលក់ដូរ ។

## តើលិខិតប្រាប់ឲ្យដឹងជាអ្វីដែលខ្ញុំត្រូវធ្វើជាងមួយដងឬ?

បាទទេ ។ គេត្រូវការលិខិតប្រាប់ឲ្យដឹងតែម្តងទេ, ដរាបណា ពត៌មានដែលផ្តល់នោះនៅតែត្រឹមត្រូវ ។ យ៉ាងណាក៏ដោយ, ពេលណាមានការផ្លាស់ប្តូរ, ឧទាហរណ៍, ឈ្មោះ, អស័យដ្ឋាន, ឬឈ្មោះពាណិជ្ជកម្ម, ឬអ្វីដែលគេធ្វើម្ហូបអាហារដែលគេទាក់ទិនជាមួយ, នៅពេលនោះលោកអ្នកត្រូវតែប្រាប់ភ្នាក់ងារអនុវត្តច្បាប់ស្តីពីការកែប្រែនេះមុននឹងវាកើតឡើង ។

## តើមានក្រដាសបំពេញលិខិតប្រាប់ឲ្យដឹងឬទេ?

គំរូក្រដាសបំពេញលិខិតប្រាប់ឲ្យដឹងបានត្រូវគេធ្វើសំរាប់ប្រើប្រាស់ដោយភ្នាក់ងារអនុវត្តច្បាប់តំបន់ ។ អ្នកខ្លះគេប្រហែលជ្រើសរើសប្រើគំរូផ្សេងៗទៀត, ក៏ប៉ុន្តែគេគួរតែសួរសំណួរដូចៗគ្នា ។ ឯកសារគោលការណ៍នៃលិខិតប្រាប់ឲ្យដឹង ANZFA ផ្តល់ការណែនាំថែមទៀតស្តីពីប្រធានបទនេះ ។ ឯកសារនេះនឹងត្រូវគេបោះពុម្ពនៅក្នុងខែមិថុនា ឆ្នាំ២០០១ ។ វាក៏អាចរកបាននៅតាមវែបសៃ ANZFA ។ ចូរទាក់ទងនឹងសាលាសង្កាត់លោកអ្នក ឬក្រុមសុខភាពតំបន់ សំរាប់យកពត៌មានស្តីពីតម្រូវការនៃលិខិតប្រាប់ឲ្យដឹងនិងក្រដាសបំពេញនៃលិខិតប្រាប់ឲ្យដឹងសំរាប់តំបន់លោកអ្នក ។

## តើត្រូវការពត៌មានបន្ថែមទៀតឬទេ?

អត្ថបទនៃក្បួនខ្នាត, ការណែនាំលើអ្វីទាំងអស់នេះ, និងក្រដាសហេតុការណ៍ដ៏ទៃទៀតនិងឯកសារគាំទ្រអាចរកបាននៅតាមវែបសៃ(www.anzfa.gov.au)។ នៅពេលដែលក្បួនខ្នាតនេះនឹងអនុវត្តនៅក្នុងរដ្ឋនិងដែនដីនិមួយៗ, ពាណិជ្ជកម្មម្ហូបអាហារក៏នឹងអាចរកឱវាទផ្ទាល់បានពីភ្នាក់ងារសុខភាពខាងបរិស្ថាននៅតាមសាលាសង្កាត់គេ; ឬពីក្រសួងសុខភាពរដ្ឋ ឬដែនដីគេ ឬក្រសួងកិច្ចបំរើខាងសុខភាពនិងក្រុមសុខភាពសាធារណៈ ។

ពត៌មានពិស្តារសំរាប់ទាក់ទងក្រសួងសុខភាពរដ្ឋនិងដែនដីនិងសាលាសង្កាត់លោកអ្នកមានបញ្ចូលនៅក្នុងក្រដាសហេតុការណ៍នៃក្បួនខ្នាតសុវត្ថិភាពនៃម្ហូបអាហារ-ប្រភពពត៌មាននិងឱវាទ (Food Safety Standards-Source of information & advice).

Australia New Zealand Food Authority
P O Box 7186
Canberra MC ACT 2610
Tel: 02 6271 2222 Fax: 02 6271 2278

Website: www.anzfa.gov.au
Email: advice@anzfa.gov.au
Advice Line: 1300 652 166

Australia New Zealand Food Authority
P O Box 10559
Wellington NZ 6036
Tel: 04 473 9942 Fax: 04 473 9855

Website: www.anzfa.govt.nz
Email: nz.reception@anzfa.gov.au
Advice Line: 0800 441 571